# ក្រសួងអប់រំ LBUSD ឃ្លាំមើលភាពកើនឡើងនៃជម្ងឺ កូវិដ

ក្រសួងអប់រំ ឡុងប៊ិច បន្តការឃ្លាំមើលភាពកើនឡើងនៃជម្ងឺ កូវិដ-១៩ នៅតាមតំបន់ និង ទូទាំងប្រទេស ដោយប្រើលទ្ធផល និង ក្បួនណែនាំពីក្រសួងរបស់រដ្ឋ និង ប្រចាំតំបន់សម្រាប់ដោះស្រាយស្របជាបន្តបន្ទាប់ទៅ ។

មួយសប្តាហ៍កន្លងមក គឺមានបុគ្គលិកនៅតាមសាលារៀន និង ការិយាល័យថ្នាក់លើ បីបួន កន្លែងត្រូវបានសុំអោយសម្រាកនៅផ្ទះចំនួនពេល ១៤ ថ្ងៃ តាមការប្រយ័ត្នទុកជាមុន ដោយមូលហេតុថា ប្រហែលជាអាចមានការឆ្លងជម្ងឺ កូវិដ ។

ភាពកើនឡើងនៃជម្ងឺ កូវិដ-១៩ ក៏បានបណ្តាលផងដែរអោយមានការបើកកិច្ចប្រជុំគណៈកម្មការនាយកផ្នែកសិក្សាធិការដែលធ្វើឡើងតាមរយៈ អនឡាញ ទាំងស្រុងនៅក្នុងសប្តាហ៍នេះ ហើយក្រសួងអប់រំ ឡុងប៊ិច កំពុងតែគិតគូរមើលឡើងវិញអំពីការប្រើពេលវេលាបញ្ជូនបន្តិចម្តងៗសម្រាប់សិស្សខ្លះ ដែលមានភាពពិការ អោយត្រឡប់ចូលសាលារៀនវិញ ។

ក្រសួងអប់រំ LBUSD បន្តការស្វែងរកមើលអំពីមធ្យោបាយអាចជ្រើសរើស ធ្វើបានសម្រាប់បញ្ជូនសិស្សខ្លះ ដែលរៀនថ្នាក់ធី-ឃេ ទៅ ថ្នាក់ទី២ អោយត្រឡប់ចូលរៀនក្នុងថ្នាក់ផ្ទាល់វិញ តាមវិធីប្រើការលើកលែងពីច្បាប់ ។ កម្មវិធីកីឡា និង ភ្លេងគឺនៅពេលនេះ គ្មានការធានាជួយបានទេស្ថិតនៅក្រោមការលើកលែងពីច្បាប់ ។

ក្រសួងអប់រំ ឡុងប៊ិច នឹងបន្តការឃ្លាំមើលយ៉ាងជិតដល់អំពីលទ្ធផលនៃជម្ងឺ កូវិដ នៅពេលវិស្សមកាលរដូវរងាជិតចូលមកដល់ ។ ដើម្បីបង្កើនទៅមុខសម្រាប់បើកសាលារៀនទាំងស្រុងឡើងវិញ ដែលជាការបង្ហាត់មេរៀននៅតាមថ្នាក់ផ្ទាល់គឺដំបូងគេ ឡូស អ៊ែនជេឡេស ខោនធី ត្រូវបង្ហាញតាមការតម្រូវមួយ ដែលឈានចេញពីជាន់ថ្នាក់សព្វថ្ងៃជាពណ៌ ស្វាយ (purple tier) ឬ កម្រិតតឹងរ៉ឹងជាងគេ ទៅកាន់ជាន់ថ្នាក់បន្ទូរជាពណ៌ ក្រហម (red tier) ។ បន្ទាប់ទៅ ខោនធី ត្រូវស្ថិតនៅក្នុងកម្រិតជាន់ថ្នាក់ជាពណ៌ ក្រហម នោះអោយបានចំនួនពេល ដប់បួន ថ្ងៃជាបន្ថែមទៀត ។ ក្រសួងអប់រំ LBUSD បានប្រុងទុកជាស្រេចហើយសម្រាប់ធ្វើស្របដំណាក់ការបញ្ជូនសិស្សត្រឡប់ចូលសាលារៀនវិញ នៅពេលណាបញ្ហាជម្ងឺ កូវិដ មានការថយចុះ ។

លុះត្រាតែដល់ពេលនោះសិន គឺនៅពេលឥឡូវនេះ ទាំងគ្រូបង្រៀន រួមទាំងបុគ្គលិកទូទៅនឹងបន្តការប្រឹងប្រែងផ្តល់កម្មវិធីសិក្សាជាកម្រិតខ្ពស់បំផុតតាមរយៈរៀន អនឡាញ ។ សូមអរគុណដ៏ជ្រៅជ្រះចំពោះសេចក្តីគាំទ្រមកពីម្នាក់ៗនៅក្នុងសហគមន៏នៃក្រសួងអប់រំ LBUSD ។